## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៥០ "គ"

ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៣

ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣

-សំណុំរឿងស៊ើបសួរលេខ ២៨៤

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣

-សំណុំរឿងជំនុំជម្រះលេខ ៧៧៤

ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ០២:៣០ រសៀល និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ៩:០០ ព្រឹក នៅសាលសវនាការ "គ" នៃសាលាដំបូងខេត្តកំពង់ស្ពឺ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៣ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ដែលមាន៖

-ជនជាប់ចោទ៖

១-ឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើត និងមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] សំអឿន "រស់" ម្តាយឈ្មោះ [redacted] ណារិន "រស់" ប្រពន្ធឈ្មោះ [redacted] វណ្ណារ័ត្ន "រស់" មានកូន ០១ នាក់ ជានីតិជន ទោសពីមុនគ្មាន។

-ឃាត់ខ្លួនថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨០ "ឈ" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។

ជាប់ចោទពីបទ **ឆបោក** និងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅភូមិស្រែត្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ឈ្មោះ [redacted] វិចៃ ([redacted] VICHAI) ភេទប្រុស អាយុ ៣១ឆ្នាំ កើតថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩០ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើត [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្នក្រុម១០ ភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។៧



Scanned with CamScanner

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៨ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

៣-ឈ្មោះ [redacted] នីត ([redacted] NIT) ភេទស្រី អាយុ ១៧ឆ្នាំ កើតថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៤ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើត[redacted]ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តតាកែវ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៥ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

៤-ឈ្មោះ [redacted] ប៊ុនធឿន ([redacted]BUNTHOEURN) ភេទប្រុស អាយុ ១៨ឆ្នាំ កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០២ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted]ទីកន្លែងកំណើត[redacted]កណ្តាល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកណ្តាល។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៧ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

៥-ឈ្មោះ[redacted]ស៊ីណែត [redacted]SINETH) ភេទស្រី អាយុ ២៥ឆ្នាំ កើតថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិអូរព្រើស ឃុំអូរតាវៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៦ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣។

ជាប់ចោទពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

**-ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ៖**

១-ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នភូមិព្រៃរំដួលខាងលិច ឃុំបសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

២-ឈ្មោះ [redacted]សីឡា ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នភូមិដំបូកស ឃុំក្សេមក្សាន្ត ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣-ឈ្មោះ[redacted] នឿន ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារ ទីលំនៅបច្ចុប្បន្នភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

៤-ឈ្មោះ [redacted] បូរ៉ាត់ ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារ ទីលំនៅបច្ចុប្បន្នភូមិស្រែគ្រោក ឃុំបសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

៥-ឈ្មោះ [redacted]សុភា ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នផ្ទះលេខ សេ៦៤ ផ្លូវលេខ ០៧ បុរីញ៉ូថោន ភូមិអង្គ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

៦-ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នភូមិបឹងស្នុក ឃុំបសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

៧-ឈ្មោះ [redacted]ចន្ធូ ភេទស្រី អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរអាជីវករ ទីលំនៅបច្ចុប្បន្នភូមិសំព័រ ឃុំបសេដ្ឋ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បូរ៉ា។



Scanned with CamScanner

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ បានប្រើល្បិចឆបោកខ្ចីចងការប្រាក់ពីជនរងគ្រោះចំនួន ០៧នាក់ ដោយប្រាប់ថា យកឱ្យគេខ្ចីបន្ត ដើម្បីបង់ផ្តាច់ធនាគារក្នុងខេត្តកំពង់ស្ពឺ ហើយសន្យាឱ្យការប្រាក់ខ្ពស់មកជនរងគ្រោះវិញ ទើបធ្វើឱ្យជនរងគ្រោះទាំង ០៧នាក់ មានការជឿជាក់ ហើយព្រមប្រគល់ប្រាក់ឱ្យជនជាប់ចោទដោយក្នុងនោះ ១.ជនរងគ្រោះឈ្មោះ [redacted] ធឿន បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក, ២.ឈ្មោះ [redacted] សីឡា បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក, ៣.ឈ្មោះ [redacted] បូរ៉ាត់ បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក, ៤.ឈ្មោះ [redacted] វណ្ណា បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក (ប្រគល់តាមរយៈឈ្មោះ [redacted] បូរ៉ាត់), ៥.ឈ្មោះ [redacted] សុភ័ណ្ឌ បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ១៩,៨០០ (មួយម៉ឺនប្រាំបួនម៉ឺនប្រាំបីរយ) ដុល្លារអាមេរិក, ៦.ឈ្មោះ [redacted] សុភា បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមរិក និង៧.ឈ្មោះ [redacted] ចន្ធូ បានប្រគល់ប្រាក់ឱ្យជនជាប់ចោទចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក។

បន្ទាប់ពីទទួលបានប្រាក់ពីជនរងគ្រោះហើយ ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានយកប្រាក់មួយចំនួនទៅលេងល្បែងអនឡាញ (បាការ៉ាត់ និងឡូតូ) ដោយទំនាក់ទំនងបញ្ចូលទឹកប្រាក់តាមរយៈគណនីធនាគារ ABA ឈ្មោះ [redacted] VICHAI មានគណនីលេខ ០០២ ៣៩៦ ២៩៦ និងគណនី ABA ឈ្មោះ [redacted] NIT មានគណនីលេខ ០០៤ ៩៧៦ ៨០៤ ប្រាក់មួយចំនួនជនជាប់ចោទបានយកទៅបង្វិលធ្វើជាការប្រាក់ឱ្យម្ចាស់បំណុលផ្សេងទៀត និងប្រាក់មួយចំនួនទៀតជនជាប់ចោទបានចាយវាយប្រចាំថ្ងៃ។

ក្រៅពីគណនីធនាគារ ABA ទាំង ០២ខាងលើ ឈ្មោះ នាក់ បូរ៉ា ក៏ធ្លាប់បានផ្ញើប្រាក់ទៅគណនីចំនួន ០២ផ្សេងទៀតផងដែរ ដើម្បីបញ្ចូលប្រាក់លេងល្បែងអនឡាញ (បាការ៉ាត់ និងឡូតូ) ក្នុងនោះមានគណនីធនាគារ ABA ឈ្មោះ [redacted] BUNTHOEURN មានគណនីលេខ ០០៤ ០០២ ៧៦០ និងគណនីធនាគារ ABA ឈ្មោះ [redacted] SINETH មានគណនីលេខ ០០១ ២៦០ ៧៥៥។

-បានឃើញ របាយការណ៍សំយោគលេខ ០២/២៣ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៨២ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦៥៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។



Scanned with CamScanner

-បានឃើញ ដីកាដំណោះស្រាយលេខ ៦៤២ “ឈ” ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

## នាពេលសវនាការ

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន បានបញ្ជាក់ថា៖ កូនក្ដីរបស់ខ្លួនបានទទួលដំណឹងពីការកោះហៅរួចហើយ ទើបពួកគាត់ពឹងពួកខ្លួនការពារសិទ្ធិឱ្យពួកគាត់ តែពេលនេះពួកគាត់ទាំង ០២នាក់ អវត្តមាន។

-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] បូរ៉ាត់, ឈ្មោះ [redacted] នឿន, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] ចន្ទូ, ឈ្មោះ [redacted] សុភ័ណ្ឌ និងឈ្មោះ [redacted] សីឡា តាមរយៈទូរស័ព្ទ ចំណែកឈ្មោះ [redacted] សុភា ខ្លួនមិនស្គាល់នោះទេ។ ខ្លួនបានទទួលលុយពីឈ្មោះ [redacted] បូរ៉ាត់ ប្រហែលចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក, ពីឈ្មោះ [redacted] នឿន ប្រហែលចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក, ពីឈ្មោះ [redacted] វណ្ណា ប្រហែលចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក, ពីឈ្មោះ [redacted] សុភ័ណ្ឌ ប្រហែលចំនួន ១៩០,០០០ (ដប់ប្រាំបួនម៉ឺន) ដុល្លារអាមេរិក, ពីឈ្មោះ [redacted] ចន្ទូ ប្រហែលចំនួន ១៦០,០០០ (ដប់ប្រាំមួយម៉ឺន) ដុល្លារអាមេរិក និងឈ្មោះ [redacted] សុភា ធ្លាប់ចេញចូលប្រហែល ១៨០,០០០ (ដប់ប្រាំបីម៉ឺន) ដុល្លារអាមេរិក និងពីឈ្មោះ [redacted] សីឡា ប្រហែលចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក។ ការទទួលលុយពីពួកគាត់ទាំង ០៧នាក់ ម្ដងបន្តិច ទទួលតាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ ពេលទទួលលុយដំបូង គឺទទួលពីឈ្មោះ នួន នឿន និងឈ្មោះ សេង សីឡា បន្ទាប់មកឈ្មោះ [redacted] បូរ៉ាត់។ ពួកគាត់ព្រមឱ្យលុយមកខ្លួន ដោយសារពីដំបូងខ្លួនជាបុគ្គលិកធនាគារ ABA តែពួកគាត់មិនដឹងថាខ្លួនឈប់នោះទេ។ ខ្លួនឈប់ធ្វើការជាបុគ្គលិកធនាគារនៅខែមករា ឆ្នាំ២០២២ ដែលមានតួនាទីជាមន្ត្រីឥណទានថ្នាក់មធ្យម។ ខ្លួនបានយកប្រាក់ពីពួកគាត់បានដោយសារ ខ្លួនតែងតែជួយអតិថិជនផ្ដាច់ពីធនាគារមួយ រួចទៅខ្ចីធនាគារមួយទៀត ដើម្បីអតិថិជនអាចយកប្រាក់បន្ថែមពីធនាគារមួយទៀត ដោយពេលអតិថិជនត្រូវផ្ដាច់ធនាគារទី១ គឺត្រូវខ្ចីប្រាក់ឯកជនយកមកផ្ដាច់ ដូចនេះខ្លួនក៏បានយកប្រាក់ដើមបណ្ដឹងរដ្ឋប្បវេណីទៅឱ្យអតិថិជន ដើម្បីបង់ផ្ដាច់ធនាគារទី១ ដោយអតិថិជនឱ្យការប្រាក់មកវិញតាមការចចារ។ ខ្លួនបានធ្វើកិច្ចសន្យាខ្ចីប្រាក់ជាមួយអតិថិជន តែមិនបានធ្វើកិច្ចសន្យាខ្ចីប្រាក់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ ឧបមាថាប្រាក់ដើមចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ខ្លួនឱ្យការប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណីជាង ២០០ (ពីររយ) ដុល្លារអាមេរិក ហើយខ្លួនបានទទួលការប្រាក់ពីអតិថិជនជាង ៣០០ (បីរយ) ដុល្លារអាមេរិក ដូចនេះខ្លួននៅសល់ការប្រាក់ប្រហែល ១០០ (មួយរយ) ដុល្លារអាមេរិកបន្ទាប់ពីឱ្យការប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណី។ ពេលនោះខ្លួនរកពួកគាត់មុន គឺរកពីឈ្មោះ [redacted] នឿន, សេង សីឡា និងឈ្មោះ [redacted] បូរ៉ាត់។ ក្រោយមកទៀត ខ្លួនរកអតិថិជនបង់ផ្ដាច់ធនាគារបានកាន់តែច្រើន ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានរកអ្នកផ្សេងទៀតមកដាក់បន្ត។ ដោយរូបភាពនេះមិនមែនជាការខ្ចីប្រាក់ចងការទេ គឺខ្លួន និងដើមបណ្ដឹងរដ្ឋប្បវេណីរកស៊ីជាមួយគ្នា ដើម្បីចំណេញការប្រាក់ពីអតិថិជនដែលចង់បានលុយយកទៅបង់ផ្ដាច់ជាមួយធនាគារ។ ខ្លួនបានយកប្រាក់ពីដើមបណ្ដឹងរដ្ឋប្បវេណីទៅធ្វើការផ្ដាច់ឱ្យអតិថិជនបែបនេះបានតែរយៈពេលខ្លីទេ គឺប្រហែល ៥ខែប៉ុណ្ណោះ ក្រោយមកខ្លួនបានឈប់ធ្វើការនៅធនាគារ រួចខ្លួនក៏មិនបានយកលុយដែលទទួលបានពីដើមបណ្ដឹងរដ្ឋប្បវេណីទៅបង់ផ្ដាច់ធនាគារឱ្យអតិថិជនទៀតដែរ តែខ្លួនបានយកប្រាក់នេះទៅលេងល្បែង ផ្គត់ផ្គង់គ្រួសារ និងឱ្យការប្រាក់ត្រឡប់ទៅដើមបណ្ដឹងរដ្ឋប្បវេណីទាំង ០៧នាក់វិញខ្លះ ហើយដើមបណ្ដឹងរដ្ឋប្បវេណីមិនដឹងថាខ្លួនឈប់ផ្ដាច់ធនាគារឱ្យអតិថិជននោះទេ។ ពេលខ្លួនទាក់ទងឈ្មោះ

សេង សីឡា យកលុយផ្ដាច់ធនាគារឱ្យអតិថិជនផ្សេងបានរយៈពេលខ្លី ហើយពេលដែលខ្លួនឈប់ធ្វើការនៅធនាគារ ខ្លួនមិនបានប្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីទេ លើកលែងតែឈ្មោះ [redacted] សីឡា ដែលបានដឹងថាខ្លួនឈប់។ នៅចុងឆ្នាំ២០២២ ខ្លួនបានប្រាប់ឈ្មោះ [redacted] បូរ៉ាត់ និងឈ្មោះ [redacted] សុភ័ណ្ឌ ថាខ្លួនបានឈប់ធ្វើការនៅធនាគារដែរ។ តាំងពីឆ្នាំ២០២១ ពេលខ្លួនយកប្រាក់ពីដើមបណ្ដឹងរដ្ឋប្បវេណី ខ្លួនបានឱ្យការប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណីជាប់រហូតដល់ពេលចាប់ខ្លួន។ ខ្លួនបានឱ្យការប្រាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណីសរុបប្រហែល ៤០០,០០០ (សែសិបម៉ឺន) ដុល្លារអាមេរិក តែម្នាក់ទទួលបានប៉ុន្មាន ខ្លួនមិនចាំនោះទេ តែអាចឆែកចម្លើយនៅសមត្ថកិច្ចបាន។ ម្យ៉ាងទៀតពេលឱ្យការប្រាក់នោះមិនបានធ្វើកិច្ចសន្យាទេ តែបានបាញ់តាមកុងធនាគារ។ ដំបូងខ្លួនបានយកលុយពីឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] បូរ៉ាត់ ទៅផ្ដាច់ធនាគារឱ្យគេពិតមែន មិនបានយកទៅលេងល្បែងនោះទេ។ លុះពេលយកលុយពីដើមបណ្ដឹងរដ្ឋប្បវេណីក្រោយៗទៀត ទើបយកទៅលេងល្បែង និងបង្វិលការប្រាក់ឱ្យពួកគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណីវិញ។ បច្ចុប្បន្នខ្លួនមិនមានលទ្ធភាព និងទ្រព្យសម្បត្តិសម្រាប់សងប្រាក់ដើមបណ្ដឹងរដ្ឋប្បវេណីទាំង ០៧នាក់នោះទេ។ លុយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ខ្លួនមិនបានយកទិញទ្រព្យសម្បត្តិនោះទេ គឺទិញបានឡាន Camry ចំនួន ០១គ្រឿង តែដើមបណ្ដឹងរដ្ឋប្បវេណីបានដកយកចែកគ្នាអស់ហើយ។ ខ្លួនរៀនចប់បរិញ្ញាបត្រខាងធនាគារ ហើយបានធ្វើការងារជាមន្ត្រីឥណទានរបស់ធនាគារ ABA។ មិនមានមេនៅពីលើខ្លួននោះទេ។ ចំពោះប្រាក់ដែលយកពីដើមបណ្ដឹងរដ្ឋប្បវេណីទាំង ០៧នាក់ប្រហែលចំនួន ១,៣០០,០០០ (មួយលានបីសែន) រៀល។ ខ្លួនយល់ព្រមដោយស្ម័គ្រចិត្តឱ្យឡានទៅឈ្មោះ [redacted] ចន្ធូ មានតម្លៃ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ហើយក៏ព្រមឱ្យលុយទៅឈ្មោះ [redacted] បូរ៉ាត់ និងឈ្មោះ [redacted] សីឡា ម្នាក់ចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ដោយឱ្យពួកគាត់សម្រាប់កាត់ថ្លៃការប្រាក់។ ដោយពេលនោះកាត់ប្រាក់ដើម ហើយបានផ្ដិតមេដៃលើកិច្ចសន្យា តែខ្លួនមិនបានមើលកិច្ចសន្យាទេ ដោយសារកំពុងច្របូកច្របល់ និងស្មារតីមិននឹងនរ ព្រោះជំពាក់គេច្រើនពេក។ ចំពោះលុយក្នុងកុងរបស់ខ្លួនចំនួន ២,០០០ (ពីរពាន់) ដុល្លារអាមេរិក គឺពួកគាត់ឱ្យខ្លួនដោះលេខកូដ ហើយពួកគាត់ជាអ្នកបាញ់យកលុយខ្លួនឯង ខ្លួនមិនបានបាញ់ឱ្យគាត់នោះទេ។ ឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] សីឡា បាញ់លុយមកកុងរបស់ខ្លួនផ្ទាល់។ ឈ្មោះ [redacted] ចន្ធូ និងឈ្មោះ [redacted] វណ្ណា ស្គាល់តាមរយៈឈ្មោះ [redacted] បូរ៉ាត់ ហើយដំបូងៗពួកគាត់ឱ្យលុយមកខ្លួនតាមរយៈឈ្មោះ [redacted] បូរ៉ាត់ យូរៗទៅក៏បានបាញ់មកកុងរបស់ខ្លួនផ្ទាល់វិញ។ ខ្លួនជំពាក់ប្រាក់ដើមឈ្មោះ [redacted] បូរ៉ាត់ ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] ចន្ធូ ចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក, ឈ្មោះ [redacted] សីឡា ចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] សុភ័ណ្ឌ ចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក, ឈ្មោះ [redacted] វណ្ណា ចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក, ឈ្មោះ [redacted] នឿន ចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងលុយរបស់ឈ្មោះ [redacted] សុភា ខ្លួនចាំមិនច្បាស់ទេ។ ខ្លួនបានឱ្យការប្រាក់ទៅឈ្មោះ [redacted] សីឡា ប្រហែលចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។ ចំណែកការប្រាក់សម្រាប់អ្នកផ្សេងៗទៀត អាចបញ្ជាក់ចំនួនបានតាមប្រវត្តិគណនីធនាគារ។ ខ្លួនចាប់ផ្ដើមលេងល្បែងបាការ៉ាត់នៅឆ្នាំ២០២១ លុះពាក់កណ្ដាលឆ្នាំ២០២២ ខ្លួនក៏ចាប់ផ្ដើមលេងល្បែងឡូតូ។ ខ្លួនលេងល្បែងដោយខ្លួនឯង ពុំមាននរណាបញ្ចុះបញ្ចូលនោះទេ។ ខ្លួនលេងបាកាត់តាម Page Facebook: BallKh។ ខ្លួនមិនដឹងថា Page នោះ ត្រូវច្បាប់ឬអត់ទេ។ ខ្លួនដាក់លុយលេងតាមរយៈវេរលុយឱ្យគេតាមធនាគារ ABA តែមិនចាំថាវេរឱ្យឈ្មោះ [redacted] វិរៈ និងឈ្មោះ [redacted] នីត ពេលលេងបាកាត់ ឬលេងឡូតូនោះទេ។ ការលេងបាកាត់ជាលុយដុល្លារដោយវេរលុយឱ្យឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ស៊ីណែត ហើយលេងឡូតូជាលុយខ្មែរ។ កន្លងមកខ្លួនធ្លាប់វេរឱ្យឈ្មោះ [redacted]



Scanned with CamScanner

ប៊ុនធឿន និងឈ្មោះ [redacted] ស៊ីណែត ដែរ។ ខ្លួនលេងឡូតូតាមតេឡេក្រាម មិនចាំឈ្មោះនោះទេ ដោយវេរលុយខ្មែរឱ្យគេ ចំណែកពេលលេងបាកាវ៉ាត់ គឺវេរលុយឱ្យគេជាដុល្លារអាមេរិក។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ទីត និងឈ្មោះ [redacted] ប៊ុនធឿន នៅក្រៅទេ។ ខ្លួនលេងដោយវេរលុយតាមកុង ABA ទៅឱ្យពួកគាត់។ ខ្លួនលេងល្បែងអនឡាញ ដោយវេរលុយតាមកុងធនាគារ គឺដាក់វេរលុយឱ្យគេមុន ពេលឈ្នះគេវេរលុយឱ្យមកវិញ តែខ្លួនលេងមិនឈ្នះទេ។ ខ្លួនចេះលេងល្បែងអនឡាញនេះ ដោយសារឃើញគេលេងតាមហាងកាហ្វេ។ ខ្លួនលេងល្បែងតាម App Ballkh បាកាវ៉ាត់ និងឡូតូ តែខ្លួនមិនដឹងថាមានច្បាប់ឬអត់នោះទេ។ លេងបាកាវ៉ាត់ដំបូង ខ្លួនបានវេរលុយឱ្យឈ្មោះ [redacted] ស៊ីណែត ក្រោយមកបានវេរលុយឱ្យឈ្មោះ [redacted] ទីត។ ចំពោះឈ្មោះ [redacted] វីរៈ និងឈ្មោះ [redacted] ប៊ុនធឿន ខ្លួនបានវេរលុយឱ្យពួកគាត់ដែរ តែមិនចាំថា លេងបាកាវ៉ាត់ ឬឡូតូនោះទេ។ ចំពោះ Website Ballkh ខ្លួនលេងតែបាកាវ៉ាត់ទេ ហើយឡូតូ ខ្លួនលេងតាម Website ផ្សេង។ ខ្លួនចាប់ផ្ដើមលេងល្បែងអនឡាញតាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ដោយមួយថ្ងៃអាចឈ្នះបានប្រាក់ចំនួន ៥,000 (ប្រាំពាន់) ដុល្លារអាមេរិក ហើយបើចាញ់អាចអស់ប្រាក់ចំនួន ៥,000 (ប្រាំពាន់) ដុល្លារអាមេរិកដែរ តែភាគច្រើនចាញ់ច្រើនជាងឈ្នះ។ ខ្លួនស្គាល់ឈ្មោះ [redacted] ទីត និងឈ្មោះ [redacted] ប៊ុនធឿន តាមរយៈ Facebook ហើយធ្លាប់ទទួលលុយឈ្នះពីពួកគាត់ដែរ។ ខ្លួនលេងតែល្បែង 0២មុខនេះទេ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរ៉ាត់ បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] បូរ៉ា ព្រោះនៅភូមិជាមួយគ្នា។ គាត់ប្រាប់ខ្លួនថា គាត់ជាបុគ្គលិករបស់ធនាគារ ABA នៅស្រុកកណ្ដាលស្ទឹង ហើយខ្លួនជាមន្ត្រីឥណទានរបស់ធនាគារអេស៊ីលីដា (Acleda) នៅផ្សារស្លាបលែង។ ដំបូងឡើយឈ្មោះ [redacted] បូរ៉ា បានតេទូរស័ព្ទទាក់ទងមកខ្លួន ដើម្បីឱ្យខ្លួនរកលុយទៅបង់ផ្ដាច់ធនាគារឱ្យគេ ហើយបានការប្រាក់ចែកគ្នា (ឧទាហរណ៍៖ បើការប្រាក់បានចំនួន ៣00 (បីរយ) ដុល្លារអាមេរិក នោះខ្លួន និងឈ្មោះ [redacted] បូរ៉ា បានម្នាក់ចំនួន ១៥0 (មួយរយហាសិប) ដុល្លារអាមេរិក។ ពេលយកលុយពីដើមបណ្ដឹងរដ្ឋប្បវេណី ខ្លួន និងឈ្មោះ [redacted] បូរ៉ា បានផ្ដិតមេដៃជាមួយម្ចាស់លុយជាដើមបណ្ដឹងរដ្ឋប្បវេណី។ លុយរបស់ខ្លួនត្រូវបានឈ្មោះ [redacted] បូរ៉ា យកទៅប្រើប្រាស់អស់ចំនួន ៨0,000 (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ដោយគាត់បានឱ្យការប្រាក់មកខ្លួនក្នុង ០១សប្ដាហ៍ចំនួន ៥00 (ប្រាំរយ) ដុល្លារអាមេរិក នៅឆ្នាំ២០២១។ ការប្រាក់នេះបើខ្លួនបានចំនួន ៥00 (ប្រាំរយ) ដុល្លារអាមេរិក ឈ្មោះ [redacted] បូរ៉ា ក៏បានប្រាក់ចំនួន ៥00 (ប្រាំរយ) ដុល្លារអាមេរិក ដែរ គឺបានស្មើគ្នា។ បន្ទាប់មកមានគេរកផ្ដាច់ធនាគារទៀត ខ្លួនក៏បានទៅរកលុយពីឈ្មោះ [redacted] ចន្ទ មិនចាំចំនួនលុយ, ឈ្មោះ [redacted] សុភ័ណ្ឌ ចំនួន ២00,000 (ពីរសែន) ដុល្លារអាមេរិក, ឈ្មោះ [redacted] វណ្ណា ប្រហែលចំនួន ១00,000 (មួយសែន) ដុល្លារអាមេរិក, ឈ្មោះ [redacted] សុភា ប្រហែលជាង ១00,000 (មួយសែន) ដុល្លារអាមេរិក។ ពេលយកលុយពីពួកគាត់បានធ្វើកិច្ចសន្យាពីជនជាប់ចោទផ្ទាល់ ហើយខ្លួនបានផ្ដិតមេដៃជាមួយដែរ។ ខ្លួនមិនបានដឹងថាជនជាប់ចោទយកប្រាក់នោះទៅលេងល្បែងនោះទេ។ ជនជាប់ចោទបានឱ្យការប្រាក់រហូតដល់ពេលឃាត់ខ្លួន។ ខ្លួនដឹងរឿងគាត់លេងល្បែង ដោយសារគាត់បានសារភាពពេលដើមបណ្ដឹងរដ្ឋប្បវេ ណីទារប្រាក់ដើមពីគាត់វិញ។ ចំពោះឡាន Camry ស៊េរីឆ្នាំ១៩៩៨ របស់ឈ្មោះ [redacted] បូរ៉ា គឺឈ្មោះ [redacted] ចន្ទ ជាអ្នកយកទៅលក់ តែខ្លួនមិនដឹងលក់បានតម្លៃប៉ុន្មាននោះទេ។ លុយនៅក្នុងកុងរបស់ឈ្មោះ [redacted] បូរ៉ា មានប្រាក់ចំនួន ២,000 (ពីរពាន់) ដុល្លារអាមេរិក ហើយខ្លួនបានបាញ់យកលុយនោះចំនួន ១,000 (មួយពាន់) ដុល្លារអាមេរិក និងប្រាក់ចំនួន ១,000 (មួយពាន់) ដុល្លារទៀត ឈ្មោះ [redacted] សីឡា បានបាញ់យកទៅកាត់កងពេលឃាត់ខ្លួនគាត់។ ពេលឃាត់ខ្លួននោះ គាត់មិនបានសារភាពថា យកលុយទៅលេងល្បែងនោះទេ។ ប្រាក់ចំនួន ៨0,000 (ប្រាំបីម៉ឺន) ដុល្លារអាមេរិកនោះ គឺខ្លួនបានឱ្យទៅឈ្មោះ [redacted] បូរ៉ា ម្ដងត្រឹមតែ ១0,000 (មួយម៉ឺន) ដុល្លារអាមេរិក ទៅ



Scanned with CamScanner

២០,០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ប៉ុណ្ណោះ។ ពេលធ្វើកិច្ចសន្យា គឺម្ចាស់លុយផ្ទាល់ជាអ្នកធ្វើកិច្ចសន្យាជាមួយឈ្មោះ [redacted] បូរ៉ា ហើយគោលបំណងយកទៅផ្តាច់ធនាគារឱ្យគេ ប៉ុន្តែមិនបានសរសេរច្បាស់នោះទេ តែមានឯកសារប្រគល់ទទួលប្រាក់។ ឈ្មោះ [redacted] បូរ៉ា យល់ព្រមប្រគល់ប្រាក់ចំនួន ១,០០០ (មួយពាន់) ដុល្លាអាមេរិក មកឱ្យខ្លួនដោយស្ម័គ្រចិត្តពេលឃាត់ខ្លួនគាត់ទៅសាលាស្រុក។ ខ្លួនមិនបានទទួលប្រាក់បង្វិលវិញចំនួន ៣០០,០០០ (បីសែន) ដុល្លារអាមេរិក ពីឈ្មោះ [redacted] បូរ៉ា នោះទេ គឺធ្លាប់តែទទួលបានប្រាក់ដើមប្រហែល ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដើម្បីបង្វិលឱ្យម្ចាស់លុយវិញ។ ការបង្វិលប្រាក់ បានធ្វើឡើងតាមរយៈបាញ់តាមកុង ហើយការប្រាក់ពីឈ្មោះ [redacted] បូរ៉ា ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ ចំពោះលុយលក់ឡាន ខ្លួនមិនបានទទួលចំណែកនោះទេ។ ខ្លួនទាមទារលុយដើមចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក មិនទាមទារអ្វីផ្សេងទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ធូ បានឆ្លើយថា៖ ឡានម៉ាក Camry នោះ ខ្លួនមិនបានលក់នោះទេ គឺបានយកទៅឱ្យម្ចាស់បំណុលរបស់ខ្លួនបន្តដែរ ដោយឡាននោះបានព្រមព្រៀងជាមួយឈ្មោះ [redacted] បូរ៉ាត់ តម្លៃ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ លុយដើមរបស់ខ្លួនមានប្រហែលចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក។ តម្លៃឡាន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក យកមកទូទាត់ការប្រាក់សម្រាប់ខ្លួនម្នាក់ឯង មិនបានទូទាត់ថ្លៃដើមនោះទេ។ រឿងនេះ ខ្លួនទាមទារប្រាក់ពីគាត់ចំនួន ១៥០,០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក សល់ប្រាក់ជាង ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ទៀត ខ្លួនចោល ហើយជម្ងឺចិត្តមិនទាមទារនោះទេ។ ដំបូងឈ្មោះ [redacted] បូរ៉ាត់ ជាអ្នកទាក់ទងមកខ្លួនឱ្យយកប្រាក់ដាក់ឱ្យឈ្មោះ [redacted] បូរ៉ា ដើម្បីផ្តាច់ធនាគារឱ្យអ្នកផ្សេង ដោយឱ្យការប្រាក់ និងបង្វិលប្រាក់ដើមមកវិញ។ តាំងពីចុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ គាត់មិនបានបង្វិលប្រាក់ដើមសរុបចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក តែគាត់បានឱ្យការប្រាក់ជាប់រហូត។ ចំពោះការប្រាក់ បើប្រាក់ដើមចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក គឺបានការប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក។ ក្នុងកិច្ចសន្យា គឺឈ្មោះ [redacted] បូរ៉ាត់ ជាអ្នកខ្ចី។ ពេលខ្ចីដំបូងៗមិនមានធ្វើកិច្ចសន្យាទេ។ ចំពោះលុយរបស់ខ្លួនដែលឱ្យទៅឈ្មោះ [redacted] បូរ៉ា គឺខ្លួនក៏បានយកពីបងប្អូនខ្លះដែរ។ ក្នុងកិច្ចសន្យា ខ្លួនជាអ្នកផ្តិតមេដៃជាមួយឈ្មោះ [redacted] បូរ៉ា និងឈ្មោះ [redacted] បូរ៉ាត់ ហើយកិច្ចសន្យាខ្លួនជាអ្នករៀបចំ។ ការប្រាក់ដែលខ្លួនទទួលបានពីឈ្មោះ [redacted] បូរ៉ា ប្រហែលចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក នៃប្រាក់ដើមចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា បានឆ្លើយថា៖ ប្រាក់ដើមរបស់ខ្លួនចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក ដោយលុយរបស់ខ្លួនខ្លះ និងលុយខ្ចីពីបងប្អូនបន្តខ្លះ។ តាំងពីខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃចាប់ខ្លួនឈ្មោះ [redacted] បូរ៉ា បានឱ្យការប្រាក់មកខ្លួនរហូត។ ដោយគាត់ឱ្យការប្រាក់ចំនួន ២០០ (ពីររយ) ទៅ ៣០០ (បីរយ) ដុល្លារអាមេរិក សម្រាប់រយៈពេល ០២ ទៅ ០៣ថ្ងៃ។ ខ្លួនទាមទារសំណងលុយដើមចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកពីគាត់។ ខ្លួនស្គាល់ឈ្មោះ [redacted] បូរ៉ា តាមរយៈឈ្មោះ ស្រេង។ ប្រាក់ដើមទាំងអស់ គឺខ្លួនខ្ចីពីបងប្អូនរកស៊ីបញ្ចាំខ្លះ ដោយលុយរបស់ខ្លួនមានប្រហែលចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។ ចំពោះការប្រាក់ដែលទទួលបានតាំងពីដើម ខ្លួនមិនចាំនោះទេ។ ឯកសារស្នាមបនា ជាប្រតិបត្តិការដែលខ្លួនបានវេរលុយឱ្យឈ្មោះ [redacted] បូរ៉ា ហើយខ្លួនក៏មានប្រតិបត្តិការ ABA ដែលឈ្មោះ [redacted] បូរ៉ា វេរក្នុងកុង ABA របស់គាត់។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ណ្ឌ បានឆ្លើយថា៖ លុយដើមរបស់ខ្លួនចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក ដោយលុយរបស់ខ្លួនខ្លះ និងលុយយកពីបងប្អូនខ្លះ ហើយឱ្យឈ្មោះ [redacted] បូរ៉ា ខ្ចីតាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ពោលគឺដល់ពេលចាប់ខ្លួនតែម្ដង។ ឈ្មោះ [redacted] បូរ៉ា បានយកលុយម្ដងបន្តិចៗ។ ខ្លួនរកស៊ីលក់ឡាន។ ខ្លួនទាមទារប្រាក់ដើមចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។ ចំពោះកិច្ចសន្យា គឺខ្លួនបានធ្វើជាមួយឈ្មោះ [redacted] បូរ៉ាត់ និងឈ្មោះ [redacted] បូរ៉ា។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]វណ្ណា បានឆ្លើយថា៖ លុយដើមរបស់ខ្លួនមានចំនួន ១០៤,០០០ (មួយសែនបួនពាន់) ដុល្លារអាមេរិក ដែលបានដាក់ឱ្យគាត់ខ្ចីតាំងពីឆ្នាំ២០២១ ដល់ថ្ងៃចាប់ខ្លួន ហើយខ្លួនបានទទួលការប្រាក់រហូតដល់ពេលចាប់ខ្លួនដែរ។ ខ្លួនទាមទារប្រាក់ដើមចំនួន ១០៤,០០០ (មួយសែនបួនពាន់) ដុល្លារអាមេរិក មិនទាមទារអ្វីផ្សេងទេ។ ខ្លួនស្គាល់ជនជាប់ចោទតាមរយៈឈ្មោះ [redacted]បូរ៉ាត់។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] នឿន បានឆ្លើយថា៖ លុយដើមរបស់ខ្លួនមានចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ដែលបានឱ្យឈ្មោះ [redacted] បូរ៉ា ខ្ចីតាំងពីខែមីនា ឆ្នាំ២០២២ រហូតដល់ពេលចាប់ខ្លួន ហើយបានទទួលការប្រាក់រហូតដល់ពេលចាប់ខ្លួនដែរ។ ខ្លួនស្គាល់ជនជាប់ចោទដោយខ្លួនឯង។ ខ្លួនទាមទារតែប្រាក់ដើមចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក មកវិញទេ។ លុយទាំងអស់ជារបស់ខ្លួនផ្ទាល់ ដែលបានមកពីការលក់ដី។

-មេធាវីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ខ្លួនបានបញ្ចូលភស្តុតាងជា អាជ្ញាប័ណ្ណស្របច្បាប់របស់ក្រុមហ៊ុនឡូតូ និងភស្តុតាងបញ្ជាក់ថា កូនក្ដីរបស់ខ្លួនទាំង ០២នាក់ ជាបុគ្គលិកក្រុមហ៊ុនឡូតូ តាមកិច្ចសន្យាការងារ។ អាជ្ញាប័ណ្ណលេខកុង ស.៤.៣ ដែលបើកឱ្យដំណើរការឆ្នោតឡូតូ។ ជនជាប់ចោទឈ្មោះ [redacted] វីរៃ និងឈ្មោះ [redacted] ស៊ីណែត មិនមែនជាបុគ្គលិករបស់ក្រុមហ៊ុន ឡូតូ ៨៨៨៨ នោះទេ។ ផ្អែកតាមប្រតិបត្តិការវេរប្រាក់របស់ឈ្មោះ [redacted] បូរ៉ា គឺជនជាប់ចោទបានវេរប្រាក់ជាលុយខ្មែរមកឱ្យកូនក្ដីរបស់ខ្លួនទាំង ០២នាក់។ ដែលអាចបញ្ជាក់ថា ពួកគាត់ទាំង ០២នាក់ ពិតជាភ្នាក់ងាររបស់ក្រុមហ៊ុន ឡូតូ ៨៨៨៨ ដែលស្របតាមចម្លើយរបស់ជនជាប់ចោទ។

-មេធាវីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា៖ ក្រុមហ៊ុនឆ្នោតឡូតូធំ មានឈ្មោះ ឡូតូ ៨៨៨៨។ បុគ្គលិកម្នាក់ៗមានគណនេយ្យ Facebook ដើម្បីរកអតិថិជនរៀងៗខ្លួន ប៉ុន្តែពេលលេង គឺលេងលើ Website ឡូតូ ៨៨៨៨ ទាំងអស់។ ភ្នាក់ងារឡូតូ ៨៨៨៨ ទាំងអស់ នៅតាមហាងកាហ្វេទូទាំងប្រទេស សុទ្ធតែគ្រប់គ្រងដោយក្រុមហ៊ុនធំ។ តាមច្បាប់ការងារ កូនក្ដីរបស់ខ្លួនជានីតិជន អាចបំពេញការងារបាន។

-តុលាការឱ្យក្រឡាបញ្ជីអានបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា ដែលបានប្ដឹងថា៖ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ១៥ និង ១៥នាទី មានឈ្មោះ [redacted] ប៉ូរ៉ាត់ បានទូរស័ព្ទមកប្រាប់ខ្លួនថា "ចងការប្រាក់ជាមួយឈ្មោះ [redacted] បូរ៉ា ដើម្បីរកស៊ីដាក់ប្រាក់កម្ចីសម្រាប់ផ្ដាច់ធនាគារ ដោយក្នុងមួយថ្ងៃ ទទួលបានការប្រាក់ចំនួន ៥០ (សែសិប) ដុល្លារអាមេរិក នៃប្រាក់កម្ចីដែលមានប្រាក់ដើមចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក" ពេលលឺដូចនេះ ខ្លួនក៏ឯកភាពដោយបានប្រគល់ប្រាក់ទៅតាមរយៈឈ្មោះ [redacted] បូរ៉ាត់ ដោយសារតែឈ្មោះ [redacted] បូរ៉ា ប្រាប់ថា "គណនី ABA របស់គាត់មានគេតាម ហេតុនេះសុំបាញ់ឱ្យតាមរយៈគណនីឈ្មោះ [redacted] បូរ៉ាត់ ដើម្បីទម្លាក់ប្រាក់ទៅឱ្យគាត់"។ លុះព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ ទើបខ្លួនទម្លាក់ប្រាក់ឱ្យឈ្មោះ [redacted] បូរ៉ា ដែលមានប្រាក់ដើមចំនួន ១៧,០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។ ចាប់តាំងពីពេលនោះមកខ្លួនបានដាក់ប្រាក់កម្ចីឱ្យឈ្មោះ នាក់ បូរ៉ា ដោយបង់ប្រាក់តាមរយៈ ៧

ឈ្មោះ [redacted] បូរ៉ាត់ មកដល់ពេលបច្ចុប្បន្ន។ លុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ឈ្មោះសំ ចន្ទូ បានប្រាប់ថា "ឈ្មោះ [redacted] បូរ៉ា បានឆបោកប្រាក់ពីយើងហើយ"។ បន្ទាប់មកអ្នកចងការទាំងអស់បានទៅដោះស្រាយ ប៉ុន្តែឈ្មោះ [redacted] បូរ៉ា មិនមានលទ្ធភាពសង។ គិតមកដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ ប្រាក់ដើមសរុបរបស់ខ្លួនមានចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។ សុំទាមទារប្រាក់ដើមចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក និងសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-លោកស្រីមេធាវី [redacted] មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា ធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការដេញដោលឃើញថា ជនជាប់ចោទទទួលស្គាល់ថាខ្លួនពិតជាបានចងការប្រាក់ពីកូនក្តីរបស់ខ្លួនឈ្មោះ សេង សីឡា ចំនួន ២៩០,០០០ (ដប់ប្រាំបួនម៉ឺន) ដុល្លារអាមេរិក ពិតមែន។ កូនក្តីខ្លួនស្គាល់ជនជាប់ចោទតាមរយៈឈ្មោះ ស្រ៊ុន។ ដោយកាលពីដំបូងៗ ជនជាប់ចោទបានបង្វិលប្រាក់ដើម និងការប្រាក់មកហូរហែរ ថាបានយកទៅបង់ផ្តាច់ធនាគារឱ្យគេ ធ្វើឱ្យកូនក្តីរបស់ខ្លួនមានការជឿទុកចិត្ត បន្តផ្តល់ប្រាក់ឱ្យជនជាប់ចោទខ្ចីរហូត តែជនជាប់ចោទបែរជាយកទៅលេងល្បែង និងបង្វិលការប្រាក់ឱ្យកូនក្តីខ្លួនវិញ។ ដូចនេះសុំឱ្យផ្តន្ទាទោសជនល្មើស និងសងសំណងប្រាក់ដើមចំនួន ២៩០,០០០ (ដប់ប្រាំបួនម៉ឺន) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានសួរដេញដោលឃើញថា មានភស្តុតាង ចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពឆបោកប្រាក់របស់ជនរងគ្រោះថា យកទៅបង់ផ្តាច់ធនាគារឱ្យគេ តែធាតុពិតបានយកប្រាក់នោះទៅលេងល្បែង និងចំណាយផ្សេងៗពិតមែន។ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦៥៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ទុកដដែល។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ទីត និងឈ្មោះ [redacted] ប៊ុនធឿន មានឯកសារបញ្ជាក់ថា ជាបុគ្គលិកក្រុមហ៊ុនឡូតូ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ដូចនេះសុំរួចខ្លួនពីបទចោទ។ ចំណែកឈ្មោះ [redacted] វីរៃ និងឈ្មោះ [redacted] ស៊ីណែត សុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយការដេញដោលឃើញថា តាមអង្គហេតុជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ធ្លាប់ជាបុគ្គលិករបស់ធនាគារស្ថាបនា និងបានប្តូរមកធ្វើការជាបុគ្គលិកធនាគារ ABA វិញ។ ក្រោយមកគាត់បានរកស៊ីដោយជួយបង់ផ្តាច់បំណុលឱ្យអ្នកដែលត្រូវការ ហើយបានយកប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណី។ ពីដំបូងៗ គាត់បានយកទៅរកស៊ីពិតមែន តែក្រោយមកគាត់បានលង់ខ្លួនលេងល្បែងរហូតមិនមានប្រាក់ដើម និងការប្រាក់បង្វិលឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ សុទ្ធតែនិយាយពាក់ព័ន្ធនឹងការខ្ចីប្រាក់ ដោយមានការផ្តល់ការប្រាក់ ដូចនេះវាជាកិច្ចសន្យាខ្ចីបរិភោគ មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ តាមការបូកប្រាកដើមដែលកូនក្តីខ្លួនបានទទួលមានចំនួនជាង ១,៦០០,០០០ (មួយលានហុកសិបម៉ឺន) ដុល្លារអាមេរិក ហើយបានឱ្យការប្រាក់ទៅពួកគាត់វិញចំនួនជាង ៦០០,០០០ (ហុកសិបម៉ឺន) ដុល្លារអាមេរិក។ ពេលទូទាត់បំណុលចុងក្រោយ ឈ្មោះ [redacted] ចន្ទូ បានដកហូតឡានរបស់កូនក្តីខ្លួន ដោយពុំមែនជាការ

ស្ម័គ្រចិត្ត ដូចនេះជាបទល្មើស។ ចំណែកឈ្មោះ [redacted] បូរ៉ាត់ និងឈ្មោះ [redacted] សីឡា បានដកហូតលុយរបស់កូនក្តីខ្លួនក្នុងម្នាក់ចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ដោយបានបង្ខំកូនក្តីខ្លួនឱ្យដោះលេខកូដ និងធ្វើការបាញ់លុយយកដោយខ្លួនឯង ដូចនេះជាបទល្មើសលួច។ រឿងខាងលើមិនមែនជាការឆបោកទេ គឺជាបទរំលោភលើទំនុកចិត្ត ដោយហេតុថា កូនក្តីខ្លួនមិនបានអនុវត្តកាតព្វកិច្ចបង្វិលប្រាក់ដើមឱ្យដើមបណ្តឹងរដ្ឋប្បវេណីវិញ។ ចំពោះការចោទប្រកាន់រឿងលេងល្បែងស៊ីសង គឺពុំមានភស្តុតាងបញ្ជាក់ថា លេងល្បែងបាការ៉ាត់ជាអំពើខុសច្បាប់នោះទេ ហើយក៏ពុំមានភស្តុតាងបញ្ជាក់ថា Website បាការ៉ាត់នោះខុសច្បាប់ដែរ ដូចនេះមិនមែនលេងល្បែងខុសច្បាប់ទេ។ ចំណែកឡូតូជាក្រុមហ៊ុនឡូតូស្របច្បាប់ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ ដូច្នេះស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសកូនក្តីរបស់ខ្លួន។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីត និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនបានទទួលវេរលុយលេងឡូតូមែន ដោយគាត់ជាបុគ្គលិកខាងដាក់ប្រាក់តែក្រុមហ៊ុនឡូតូមានច្បាប់ត្រឹមត្រូវ។

-លោកមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីត និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឃើញថាតាមចម្លើយរបស់ជនជាប់ចោទមានភាពស៊ីសង្វាក់នឹងភស្តុតាងដែលបញ្ជាក់ថា កូនក្តីរបស់ខ្លួនទាំង ០២នាក់ ធ្វើការជាបុគ្គលិកក្រុមហ៊ុនឡូតូស្របច្បាប់ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ដូចនេះពុំមានបទល្មើសនោះទេ។ ម្យ៉ាងទៀតកូនក្តីខ្លួនមិនបានឆបោក និងមិនមែនជាភ្នាក់ងារលេងល្បែងខុសច្បាប់នោះទេ ដោយផ្អែកតាមមាត្រា ១ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសងខុសច្បាប់។ ដូចនេះសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួនទាំង ០២នាក់រួចផុតពីបទចោទ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បាននិយាយសំដីចុងក្រោយថា៖ សុំឱ្យតុលាការបន្ធូរបន្ថយទោស ព្រោះខ្លួនបានដឹងកំហុសហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ ឆបោក និងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅភូមិស្រែគ្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីរំឡងឆ្នាំ២០២១



Scanned with CamScanner

ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ជនជាប់ចោទឈ្មោះ [redacted] វិឆៃ ([redacted] VICHAI) , ឈ្មោះ [redacted] នីត ([redacted] NIT), ឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) និងឈ្មោះ [redacted] ស៊ីណែត ([redacted] SINETH) ត្រូវបានចៅក្រមស៊ើបសួរសម្រេចបញ្ជូនមកជំនុំជម្រះពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣-តាមរបាយការណ៍សំយោគលេខ ០២/២៣ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន បានបង្ហាញថា កាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៥ និង ៣០នាទី មានប្រជាពលរដ្ឋចំនួន ០៧នាក់ បាននាំខ្លួនបុគ្គលឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ នៅភូមិស្រែគ្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ មកប្រគល់ជូនសមត្ថកិច្ចអធិការដ្ឋាននគរបាលស្រុកបសេដ្ឋ ដើម្បីដាក់ពាក្យបណ្តឹងប្តឹងបុគ្គលខាងលើពីបទ ឆបោកប្រាក់ ចំនួន ១,១៦៤,០០០ (មួយលានដប់ប្រាំមួយម៉ឺនបួនពាន់) ដុល្លារអាមេរិក ពាក់ព័ន្ធករណីដាក់ប្រាក់វិនិយោគលើការបង់រំលោះប្តូរពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់កូនបំណុល តែបុគ្គលឈ្មោះ [redacted] បូរ៉ា បានឆបោកយកប្រាក់ប្រើប្រាស់ខុសគោលដៅ ដោយមិនបានផ្តល់ការប្រាក់ និងប្រាក់ដើមតាមកាលកំណត់។

៤-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយសារភាពគ្រប់ដំណាក់កាលថា កាលពីអំឡុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ខ្លួនបានទទួលលុយពីដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ជាបន្តបន្ទាប់សរុបប្រហែលចំនួន ១,៣០០,០០០ (មួយលានសាមសិបម៉ឺន) រៀល។ ហើយមកដល់ពេលនេះខ្លួនជំពាក់ប្រាក់ដើមឈ្មោះ [redacted] បូរ៉ាត់ ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] ចន្ធូ ចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក, ឈ្មោះ [redacted] ស៊ីឡា ចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] សុភ័ណ្ឌ ចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក, ឈ្មោះ[redacted] វណ្ណា ចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក, ឈ្មោះ[redacted] នឿន ចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងលុយរបស់ឈ្មោះ [redacted] សុភា ខ្លួនចាំមិនច្បាស់ទេ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ព្រមឱ្យលុយមកខ្លួន ដោយសារពីដំបូងខ្លួនជាបុគ្គលិកធនាគារ ABA មានតួនាទីជាមន្ត្រីឥណទានថ្នាក់មធ្យម តែពួកគាត់មិនដឹងថាខ្លួនឈប់នោះទេ ខ្លួនឈប់ធ្វើការជាបុគ្គលិកធនាគារនៅខែមករា ឆ្នាំ២០២២។ ខ្លួនបានយកប្រាក់ដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ទៅឱ្យអតិថិជនផ្សេង ដើម្បីបង់ផ្តាច់ធនាគារ ដោយប្រាក់ដើមចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ខ្លួនឱ្យការប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីជាង ២០០ (ពីររយ) ដុល្លារអាមេរិក ហើយខ្លួនបានទទួលការប្រាក់ពីអតិថិជនដែលយកទៅបង់ផ្តាច់ធនាគារជាង ៣០០ (បីរយ) ដុល្លារអាមេរិក ដូចនេះខ្លួននៅសល់ការប្រាក់ប្រហែល ១០០ (មួយរយ) ដុល្លារអាមេរិកបន្ទាប់ពីឱ្យការប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណី។ ដោយរូបភាពនេះមិនមែនជាការខ្ចីប្រាក់ចងការទេ គឺខ្លួន និងដើមបណ្តឹងរដ្ឋប្បវេណីរកស៊ីជាមួយគ្នា ដើម្បីចំណេញការប្រាក់ពីអតិថិជនដែលចង់បានលុយយកទៅបង់ផ្តាច់ជាមួយ ធនាគារ។ ខ្លួនបានយកប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ទៅធ្វើការផ្តាច់ឱ្យអតិថិជនបែបនេះបានតែរយៈពេលខ្លីទេ គឺប្រហែល ៥ខែប៉ុណ្ណោះ បន្ទាប់ខ្លួនមិនបានយកលុយដែលទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ទៅបង់ ផ្តាច់ធនាគារឱ្យអតិថិជនទៀតដែរ តែខ្លួនបានយកប្រាក់នេះទៅលេងល្បែង ផ្គត់ផ្គង់គ្រួសារ និងឱ្យការប្រាក់ត្រឡប់ទៅដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់វិញខ្លះ។



Scanned with CamScanner

៥-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរ៉ាត់ បានឆ្លើយថា ឈ្មោះ [redacted] បូរ៉ា បានតេទូរស័ព្ទទាក់ទងមកខ្លួន ហើយបានប្រាប់ខ្លួនថា "គាត់ជាបុគ្គលិករបស់ធនាគារ ABA នៅស្រុកកណ្ដាលស្ទឹង ឱ្យខ្លួនរកលុយទៅបង់ផ្ដាច់ធនាគារឱ្យគេ និងបានការប្រាក់ចែកគ្នា" (ឧទាហរណ៍៖ បើការប្រាក់បានចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក នោះខ្លួន និងឈ្មោះ [redacted] បូរ៉ា បានម្នាក់ចំនួន ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក)។ ពីឆ្នាំ២០២១ មកខ្លួនបានឱ្យលុយទៅឈ្មោះនាក់ បូរ៉ា ជាបន្តបន្ទាប់ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក។ បន្ទាប់មកមានគេរកផ្ដាច់ធនាគារទៀត ខ្លួនក៏បានទៅរកលុយពីឈ្មោះ [redacted] ចន្ធូ, ឈ្មោះ [redacted] សុភ័ណ្ឌ, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] សុភា។ ខ្លួនមិនបានដឹងថាជនជាប់ចោទយកប្រាក់នោះទៅលេងល្បែងនោះទេ។ ជនជាប់ចោទបានឱ្យការប្រាក់រហូតដល់ពេលឃាត់ខ្លួន។ ខ្លួនដឹងរឿងគាត់លេងល្បែង ដោយសារគាត់បានសារភាពពេលដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទារប្រាក់ដើមពីគាត់វិញ។

៦-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ធូ បានឆ្លើយថា ដំបូងឈ្មោះ [redacted] បូរ៉ា បានទាក់ទងមកខ្លួនឱ្យយកប្រាក់ដាក់ឱ្យគាត់ ដើម្បីយកទៅផ្ដាច់ធនាគារឱ្យអ្នកផ្សេង ដោយឱ្យការប្រាក់ខ្លួន និងបង្វិលប្រាក់ដើមមកវិញ។ តាំងពីចុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ ខ្លួនបានឱ្យប្រាក់ដើមទៅឈ្មោះ [redacted] បូរ៉ា សរុបចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក។ ចំពោះការប្រាក់ បើប្រាក់ដើមចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក គឺខ្លួនបានការប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក។ ហើយឈ្មោះ [redacted] បូរ៉ា បានឱ្យការប្រាក់មកខ្លួនជាប់រហូត។ ឈ្មោះ [redacted] បូរ៉ា មិនបានឱ្យប្រាក់ដើមមកខ្លួនវិញទេ។

៧-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា បានឆ្លើយថា កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ឈ្មោះ [redacted] បូរ៉ា បានតេទូរស័ព្ទមកខ្លួន ដោយប្រាប់ថា "សុំខ្ចីចងការ ដើម្បីយកលុយទៅបង់ផ្ដាច់ធនាគារ" ខ្លួនក៏បានឱ្យប្រាក់ទៅឈ្មោះ [redacted] បូរ៉ា ជាបន្តបន្ទាប់រហូតប្រាក់ដើមរបស់ខ្លួនសរុបចំនួន ២៤០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក ដោយគាត់ឱ្យការប្រាក់ចំនួន ២០០ (ពីររយ) ទៅ ៣០០ (បីរយ) ដុល្លារអាមេរិក សម្រាប់រយៈពេល ០២ ទៅ ០៣ថ្ងៃ។ តាំងពីខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃចាប់ខ្លួន ឈ្មោះ [redacted] បូរ៉ា បានឱ្យការប្រាក់មកខ្លួនរហូត។ លុះដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ខ្លួនបានទារប្រាក់ដើមមកវិញ តែឈ្មោះ [redacted] បូរ៉ា បានគេចវេសមិនសង។

៨-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ណ្ឌ បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ឈ្មោះ [redacted] បូរ៉ាត់ បានតេទូរស័ព្ទមកខ្លួនប្រាប់ថា "ចងការប្រាក់ជាមួយឈ្មោះ [redacted] បូរ៉ា ដើម្បីដាក់ប្រាក់កម្ចីសម្រាប់បង់ផ្ដាច់ធនាគារ ដោយក្នុងមួយសប្ដាហ៍ទទួលបានការប្រាក់ ៣៥០ (បីរយហាសិប) ដុល្លារអាមេរិក" បន្ទាប់មកខ្លួនក៏បានឱ្យលុយទៅឈ្មោះ [redacted] បូរ៉ា ខ្ចីជាបន្តបន្ទាប់ តាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ សរុបចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក។

៩-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណា បានឆ្លើយថា ខ្លួនបានឱ្យលុយទៅឈ្មោះ [redacted] បូរ៉ាត់ ខ្ចីតាំងពីឆ្នាំ២០២១ ដល់ថ្ងៃចាប់ខ្លួន សរុបចំនួន ១០៤,០០០ (មួយសែនបួនពាន់) ដុល្លារអាមេរិក ដោយខ្លួនបានទទួលការប្រាក់រហូតដល់ពេលចាប់ខ្លួនគាត់ដែរ។ ដោយកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ឈ្មោះ [redacted] បូរ៉ាត់ បានតេទូរស័ព្ទមកខ្លួនប្រាប់ថា "ចងការប្រាក់ជាមួយឈ្មោះ [redacted] បូរ៉ា ដើម្បីដាក់ប្រាក់កម្ចីសម្រាប់បង់ផ្ដាច់ធនាគារ ដោយក្នុងមួយថ្ងៃទទួលបានការប្រាក់ ៤០ (សែសិប) ដុល្លារអាមេរិក" ខ្លួនក៏បានយកលុយទៅដាក់ជាមួយឈ្មោះ [redacted] បូរ៉ា ជាបន្តបន្ទាប់មក។

១០-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] នឿន បានឆ្លើយថា កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ឈ្មោះ [redacted] បូរ៉ា បានតេទូរស័ព្ទមកខ្លួន ដោយប្រាប់ថា "សុំខ្ចីចងការ ដើម្បីយកលុយទៅបង់ផ្ដាច់ធនាគារ ដោយឱ្យការប្រាក់ ៣៥០ (បី

រយហាសិប) ដុល្លារអាមេរិក សម្រាប់រយៈពេល ០៣ថ្ងៃ” ខ្លួនក៏ឯកភាព។ តាំងពីខែមីនា ឆ្នាំ២០២២ រហូតដល់ពេលចាប់ខ្លួនឈ្មោះ [redacted] បូរ៉ា ខ្លួនបានឱ្យលុយទៅឈ្មោះ [redacted] បូរ៉ា ខ្ចី ចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ដោយបានទទួលការប្រាក់រហូតដល់ពេលចាប់ខ្លួនគាត់ដែរ។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា បានឆ្លើយថា កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ [redacted] បូរ៉ាត់ បានទូរស័ព្ទមកខ្លួនដោយប្រាប់ថា “ចងការប្រាក់ជាមួយឈ្មោះ [redacted] បូរ៉ា ដើម្បីដាក់ប្រាក់កម្ចីសម្រាប់បង់ផ្តាច់ធនាគារ ដោយក្នុងមួយថ្ងៃទទួលបានការប្រាក់ ៤០ (សែសិប) ដុល្លារអាមេរិក” ខ្លួនក៏ឯកភាព ហើយខ្លួនបានបាញ់លុយតាមរយៈកុងធនាគាររបស់ឈ្មោះ [redacted] បូរ៉ា ឱ្យឈ្មោះ នាក់ បូរ៉ា សរុបចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។ ឈ្មោះ [redacted] បូរ៉ា ពុំដែលបានបង់ការប្រាក់ និងរំលោះប្រាក់ដើមមកឱ្យខ្លួនទេ។

១២-ចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧ នាក់ និងភស្តុតាងដែលមានក្នុងសំណុំរឿង។ ដែលភាពស៊ីសង្វាក់គ្នានេះ និងការទទួលស្គាល់លុយជំពាក់ដែលត្រូវគ្នានឹងការទាមទារលុយដើមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់នោះ គឺជាអង្គហេតុ និងភស្តុតាងបញ្ជាក់ឱ្យឃើញថា កាលពីអំឡុងឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ នៅភូមិស្រែគ្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ពិតជាមានអង្គហេតុអំពើដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា មានចេតនាប្រើឧបាយកលទុច្ចរិតដោយប្រើឋានៈខ្លួនជាមន្ត្រីឥណទាននៅធនាគារកាណាឌីយ៉ា ទំនាក់ទំនងទៅដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ជឿទុកចិត្ត នាំគ្នាប្រគល់លុយឱ្យជនជាប់ចោទខ្ចីជាបន្តបន្ទាប់ ដោយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរ៉ាត់ បានប្រគល់ឱ្យសរុបចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] នឿន បានប្រគល់ឱ្យសរុបចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] សីឡា បានប្រគល់ឱ្យសរុបចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក, ឈ្មោះ [redacted] វណ្ណា បានប្រគល់ឱ្យសរុបចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក, ឈ្មោះ [redacted] សុភ័ណ្ឌ បានប្រគល់ឱ្យសរុបចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក, ឈ្មោះ [redacted] សុភា បានប្រគល់ឱ្យសរុបចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមរិក និងឈ្មោះ [redacted] ចន្ទូ បានប្រគល់ឱ្យសរុបចំនួន ១៦៣,០០០ (ដប់ប្រាំមួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដោយប្រើល្បិចថា យកលុយនោះឱ្យគេខ្ចីបន្ត ដើម្បីបង់ផ្តាច់ធនាគារ ក្នុងខេត្តកំពង់ស្ពឺ ទទួលបានការប្រាក់ខ្ពស់ ទើបធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ មានការជឿជាក់ ហើយព្រមប្រគល់ប្រាក់ឱ្យជនជាប់ចោទ ប៉ុន្តែពេលបានទទួលលុយពីដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ បែរជាជនជាប់ចោទយកប្រាក់នេះទៅលេងល្បែង ផ្គត់ផ្គង់គ្រួសារ និងឱ្យការប្រាក់ត្រឡប់ទៅដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់វិញខ្លះ ដោយមិនបានយកទៅបង់ផ្តាច់ធនាគារនោះទេ ហើយពេលដែលដើមបណ្តឹងរដ្ឋប្បវេណីទាំង ០៧នាក់ ទារប្រាក់ដើមមកវិញគេចវេសមិនសង។

១៣-នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ខ្លួនចាប់ផ្តើមលេងល្បែងបាការ៉ាត់នៅឆ្នាំ២០២១ តាម Page Facebook: BallKh ខ្លួនមិនដឹងថា Page នោះ ត្រូវច្បាប់ ឬអត់ទេ ដោយខ្លួនបានវេរលុយតាមធនាគារ ABA វេរជាលុយដុល្លារអាមេរិក ឱ្យវេរឈ្មោះ [redacted] ស៊ីណែត។ លុះពាក់កណ្តាលឆ្នាំ២០២២ ខ្លួនក៏ចាប់ផ្តើមលេងល្បែងឡូតូ តាមតេឡេក្រាម មិនចាំឈ្មោះ ដោយវេរឱ្យគេជាលុយខ្មែរទៅ វេរទៅធនាគារ ABA របស់ឈ្មោះ ឃឹម និត។ ចំពោះឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] ប៊ុនធឿន ខ្លួនបានវេរលុយឱ្យពួកគាត់ដែរ តែមិនចាំថា វេងលេងបាការ៉ាត់ ឬឡូតូនោះទេ។ ខ្លួនចាប់ផ្តើមលេងល្បែងអនឡាញតាំងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។ ខ្លួនស្គាល់ឈ្មោះ ឃឹម នីត និង



Scanned with CamScanner

ឈ្មោះ [redacted] ប៊ុនធឿន តាមរយៈ Facebook ហើយធ្លាប់ទទួលលុយឈ្នះពីពួកគាត់ដែរ។ ពេលខ្លួនលេងល្បែងឡូតូខ្លួនវេរលុយជាខ្មែរឱ្យគេ ពេលលេងល្បែងបាកាវ៉ាត់ខ្លួនវេរលុយជាដុល្លារអាមេរិកឱ្យគេ។

១៤-នៅមុខតំណាងអយ្យការ និងចៅក្រមស៊ើបសួរជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ពេលលេងល្បែងបាកាវ៉ាត់ ខ្លួនបានបញ្ចូលលុយតាមតេឡេក្រាមរបស់ឈ្មោះ [redacted] VICHAI និងបានផ្ញើលុយឱ្យឈ្មោះ [redacted] VICHAI តាមគណនី ABA លេខ ០០២ ២៩៦ ២៩៦ ដើម្បីលេងល្បែងបាកាវ៉ាត់ ចំណែកពេលលេងល្បែងឡូតូខ្លួនបានបញ្ចូលលុយតាមតេឡេក្រាមរបស់ឈ្មោះ [redacted] NIT និងបានផ្ញើលុយឱ្យឈ្មោះ [redacted] NIT តាមគណនី ABA លេខ ០០៤ ៩៧៦ ៨០៤។ និងធ្លាប់ផ្ញើប្រាក់លេងល្បែងទៅ ABA របស់ឈ្មោះ [redacted] BUNTHOEURN ដែលមានគណនីលេខ ០០៤ ០០២ ៧៦០ និងគណនី ABA របស់ឈ្មោះ [redacted] SINETH ដែលមានគណនីលេខ ០០១ ១៦០ ៧៥៥។

១៥-តាមរបាយការណ៍លេខ ABAកស្ត ២៣.០៥.០៥៤២ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ របស់ធនាគារវឌ្ឍនៈ អាស៊ីចំកាត់ សាខាខេត្តកំពង់ស្ពឺ បង្ហាញថា៖

ក-គណនីលេខ ០០២ ២៩៦ ២៩៦ ដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ធ្លាប់វេរលុយសម្រាប់លេងល្បែងបាកាវ៉ាត់ឱ្យ គឺមានឈ្មោះ [redacted] វិឆៃ ([redacted] VICHAI) កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៧០៦៨ ៦០៣៤ ជាម្ចាស់គណនី។

ខ-គណនីលេខ ០០៤ ៩៧៦ ៨០៤ ដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ធ្លាប់វេរលុយសម្រាប់លេងល្បែងឡូតូឱ្យ គឺមានឈ្មោះ [redacted] នីត ([redacted] NIT) កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១០១៤៤ ៧៦៣៤ ជាម្ចាស់គណនី។

គ-គណនីលេខ ០០៤ ០០២ ៧៦០ ដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ធ្លាប់វេរលុយសម្រាប់លេងល្បែងឱ្យ គឺមានឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០២១២ ៨៤៦៣៤ ជាម្ចាស់គណនី។

ឃ-គណនីលេខ ០០១ ១៦០ ៧៥៥ ដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ធ្លាប់វេរលុយសម្រាប់លេងល្បែងឱ្យ គឺមានឈ្មោះ [redacted] ស៊ីណែត [redacted] SINETH) កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២១០០៥៦៨៨៩ ជាម្ចាស់គណនី។

១៦-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានឆ្លើយថា ពេលខ្លួនលេងល្បែងឡូតូខ្លួនវេរជាលុយខ្មែរឱ្យគេ ពេលលេងល្បែងបាកាវ៉ាត់ខ្លួនវេរជាលុយដុល្លារអាមេរិកឱ្យគេ។ តាមចម្លើយរបស់ជនជាប់ចោទនេះ និងតាមភស្តុតាងឯកសារ ១/៥៩, ១/៦១, ១/៦៥ សបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វិឆៃ ជាអ្នកទទួល និងទូទាត់លុយសម្រាប់លេងល្បែងបាកាវ៉ាត់ ហើយជនជាប់ចោទឈ្មោះ [redacted] នីត ជាអ្នកទទួល និងទូទាត់លុយសម្រាប់លេងល្បែងឡូតូ។

១៧-តាមលិខិតលេខ ១០៤៦ សជណ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី, អាជ្ញាប័ណ្ណល្បែងផ្សងសំណាងលេខ ០៧០ គ.ល.ក CGMC ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ មាននាមករណ៍ ឡូតូ 8888 (LOTTO 8888), សេចក្ដីប្រកាសព័ត៌មានលេខ ០០៧/២២ អ.គ.ល.ក ប្រកព ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា, សេចក្ដីណែនាំស្ដីពីការធ្វើអាជីវកម្មល្បែងផ្សងសំណាងលេខ ០១៧/២២ អ.គ.ល.ក សណន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ របស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា និងភស្តុតាងផ្សេងទៀត



Scanned with CamScanner

សបញ្ជាក់ថា ល្បែងឡូតូ 8888 (LOTTO 8888) របស់ក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) ជាល្បែងដែលមានច្បាប់អនុញ្ញាតឱ្យបើកពីក្រសួងពាណិជ្ជកម្ម។

១៨-តាមកិច្ចសន្យាការងារពេញសិទ្ធិ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] នីត (KHOEM NIT) និងក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) សបញ្ជាក់ថា [redacted] នីត (KHOEM NIT) ជាបុគ្គលិករបស់ក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) តាំងពីឆ្នាំ២០២០ មកដល់សព្វថ្ងៃ។

១៩-តាមកិច្ចសន្យាការងារពេញសិទ្ធិ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ រវាងឈ្មោះ [redacted] ប៊ុនធឿន (OEURN BUN THOEURN) និងក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) សបញ្ជាក់ថា [redacted] ប៊ុនធឿន (OEURN BUNTHOEURN) ជាបុគ្គលិករបស់ក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) តាំងពីឆ្នាំ២០១៩ មកដល់សព្វថ្ងៃ។

២០-តាមការបញ្ជាក់របស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន ថា ជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន ជាបុគ្គលិកក្រុមហ៊ុនឡូតូ ដែលមានអាជ្ញាប័ណ្ណលេខកុង ស.៤.៣ ដែលបើកឱ្យដំណើរការឆ្នោតឡូតូ 8888។ ចំណែកជនជាប់ចោទឈ្មោះ [redacted] វិធៃ និងឈ្មោះ [redacted] ស៊ីណែត មិនមែនជាបុគ្គលិករបស់ក្រុមហ៊ុន ឡូតូ 8888 នោះទេ។ តាមការបញ្ជាក់របស់មេធាវីនេះ និងតាមសំអាងហេតុចំណុច ១៦ សបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] វិធៃ និងឈ្មោះ វ៉ា ស៊ីណែត ជាអ្នកទទួល និងទូទាត់លុយសម្រាប់លេងល្បែងបាការ៉ាត់។

២១-ដោយល្បែងឡូតូ 8888 របស់ក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) ជាល្បែងដែលមានច្បាប់អនុញ្ញាតឱ្យបើកពីក្រសួងពាណិជ្ជកម្មនោះ ហើយជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន ជាបុគ្គលិករបស់ក្រុមហ៊ុន ភីអេចវីស៊ីធី អេ ២៨៨៨ ឯ.ក (PHVCT A2888 Co.,LTD) នោះ ឃើញថា ការទទួល និងទូទាត់លុយសម្រាប់លេងល្បែងឡូតូ 8888 របស់ជនជាប់ចោទទាំង ០២នាក់ជាការទទួល និងទូទាត់ដោយស្របច្បាប់។

២២-ដោយល្បែងបាការ៉ាស់ ជាល្បែងដែលមិនមានច្បាប់អនុញ្ញាតឱ្យបើកពីក្រសួងពាណិជ្ជកម្មនោះ ដូចនេះការទទួល និងទូទាត់លុយសម្រាប់លេងល្បែងបាការ៉ាត់របស់ជនជាប់ចោទឈ្មោះ [redacted] វិធៃ និងឈ្មោះ [redacted] ស៊ីណែត ជាការទទួល និងទូទាត់ដោយមិនស្របច្បាប់។

២៣-តាមបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ៖ ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ជា អំពើឆបោក។

២៤-តាមបញ្ញត្តិមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន) រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល។



Scanned with CamScanner

២៥-តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង បានចែងថា ជនណាលេងល្បែងស៊ីសង ជននោះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០,០០០ (មួយម៉ឺន) រៀល ដល់ ៥០,០០០ (ប្រាំម៉ឺន) រៀល ឬដាក់គុកពីមួយសប្តាហ៍ដល់មួយខែ គឺជាបទ **លេងល្បែងស៊ីសងដោយខុសច្បាប់។**

២៦-តាមបញ្ញត្តិមាត្រា ០៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង បានចែងថា ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥,០០០,០០០ (ប្រាំលាន) រៀល ដល់ ២០,០០០,០០០ (ម្ភៃលាន) រៀល និងដាក់គុកពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ចំពោះអ្នកបើកកន្លែងលេងល្បែងស៊ីសង អ្នកកាន់កាប់ល្បែងស៊ីសង អ្នកចាត់ចែង និងភ្នាក់ងារស៊ីសង គឺជាបទ **ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់។**

២៧-តាមបញ្ញត្តិមាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង នេះ អាចកំណត់បានថា អំពើរបស់ជនជាប់ជនជាប់ចោទឈ្មោះ នាក់ បូរ៉ា គឺមានធាតុផ្សំជាបទ ឆបោក និងលេងល្បែងស៊ីសងដោយខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២៨-តាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង នេះ អាចកំណត់បានថា អំពើរបស់ជនជាប់ជនជាប់ចោទឈ្មោះ [redacted] វិឆៃ (CHHENG VICHAI) និងឈ្មោះ [redacted] ស៊ីណែត (RA SINETH) គឺមានធាតុផ្សំជាបទ ភ្នាក់ងារលេងល្បែងស៊ីសងដោយខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២៩-តាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង, អង្គហេតុដែលកើតឡើង និងភស្តុតាងក្នុងសំណុំរឿង អាចកំណត់បានថា អំពើរបស់ជនជាប់ជនជាប់ចោទឈ្មោះ [redacted] នីត (KHOEM NIT) និងឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) គឺមិនមានធាតុផ្សំជាបទ ភ្នាក់ងារលេងល្បែងស៊ីសងដោយខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ឡើយ។

៣០-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] បូរ៉ា ពីបទ ឆបោក និងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅភូមិស្រែត្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣១-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] វិឆៃ (CHHENG VICHAI) និងឈ្មោះ [redacted] ស៊ីណែត (RA SINETH) ពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣២-មិនមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] នីត ([redacted] NIT) និងឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) ពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ឡើយ។



Scanned with CamScanner

៣៣-នាពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា, ឈ្មោះ [redacted] វិចៃ និងឈ្មោះ [redacted] ស៊ីណែត គឺជានីតិជន ជាជនមានស្មារតីគ្រប់គ្រាន់ និងសមត្ថភាពពេញលេញក្នុងការយល់ដឹងពីអំពើរបស់ពួកខ្លួន និងលទ្ធផលតាមផ្លូវច្បាប់ ដូច្នេះជនជាប់ចោទទាំង ០៣នាក់ អាចទទួលខុសត្រូវនូវអំពើរបស់ពួកខ្លួនតាមផ្លូវច្បាប់បាន។

៣៤-អំពើដែលជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម និងទ្រព្យសម្បត្តិរបស់ជនរងគ្រោះ។ ជនជាប់ចោទបានឆ្លើយសារភាពគ្រប់ដំណាក់កាល។ ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកទី១។ ជនជាប់ចោទមានប្រពន្ធ និងកូនដែលត្រូវចិញ្ចឹមបីបាច់ និងថែរក្សា។ ជនជាប់ចោទក៏បាននិយាយសំដីចុងក្រោយ សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស និងបានដឹងកំហុស។

៣៥-ដោយសារមិនមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] នីត (KHOEM NIT) និងឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) គប្បីតុលាការបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៥ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ លើឈ្មោះ [redacted] នីត ([redacted] NIT) និងបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៧ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ លើឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៣៦-ជនជាប់ចោទឈ្មោះ [redacted] វិចៃ ([redacted] VICHAI) និងឈ្មោះ [redacted] ស៊ីណែត ([redacted] SINETH) បានប្រព្រឹត្តបទមជ្ឈិម ហើយជនជាប់ចោទទាំង ០២នាក់បានព្យាយាមគេចខ្លួន មិនចូលមកឆ្លើយដោះសារមុខតុលាការនោះទេ នោះយោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] វិចៃ និងឈ្មោះ [redacted] ស៊ីណែត ទៅពន្ធនាគារខេត្តកំពង់ស្ពឺ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

៣៧-ដោយតុលាការសម្រេចបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ [redacted] វិចៃ ([redacted] VICHAI) និងឈ្មោះ [redacted] ស៊ីណែត ([redacted] SINETH) ទៅពន្ធនាគារខេត្តកំពង់ស្ពឺ យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយនោះ គប្បីតុលាការសម្រេចបញ្ឈប់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] វិចៃ ([redacted] VICHAI) លេខ ៣៤៨ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ និងដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ស៊ីណែត ([redacted] SINETH) លេខ ៣៤៦ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៣៨-ក្នុងរឿងនេះដើមបណ្តឹងរដ្ឋប្បវេណី៖

ក-ឈ្មោះ [redacted] ធឿន បានប្តឹងទាមទារប្រាក់ដើមចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។

ខ-ឈ្មោះ [redacted] សីឡា បានប្តឹងទាមទារប្រាក់ដើមចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

គ-ឈ្មោះ [redacted] បូរ៉ាត់ បានប្តឹងទាមទារប្រាក់ដើមចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក។

ឃ-ឈ្មោះ [redacted] ណ្ណា បានប្តឹងទាមទារប្រាក់ដើមចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក។

ង-ឈ្មោះ [redacted] សុភ័ណ្ឌ បានប្តឹងទាមទារប្រាក់ដើមចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។

ច-ឈ្មោះ [redacted] សុភា បានប្តឹងទាមទារប្រាក់ដើមចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។

ឆ-ឈ្មោះ [redacted] ចន្ទ បានប្តឹងទាមទារប្រាក់ដើមចំនួន ១៥០,០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។



Scanned with CamScanner

ពីជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ឃើញថាការទាមទារនេះស្របតាមមាត្រា ១៣ និងមាត្រា ១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការសម្រេចឱ្យជនជាប់ចោទសងដោយយោងតាមការខូចខាតជាក់ស្តែង និងផលប៉ះពាល់ជាក់ស្តែងដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរង ស្របតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣៩-វត្ថុចាប់យកមាន ប្រាក់ដុល្លារចំនួន ២,៣០០ (ពីរពាន់បីរយ) ដុល្លារអាមេរិក និងប្រាក់រៀលចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល ជាប្រាក់ដែលពាក់ព័ន្ធនឹងការលេងល្បែង និងមានតម្កល់ដែលត្រូវរក្សាទុក គប្បីរឹបអូសជាសម្បត្តិរដ្ឋ តាមបញ្ញាតិមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

៤០-មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា ធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យផ្តន្ទាទោសជនល្មើស និងសងសំណងប្រាក់ដើមចំនួន ២៩០,០០០ (ពីរសែនប្រាំបួនម៉ឺន) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សីឡា ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៤១-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន រក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] បូរ៉ា, ឈ្មោះ [redacted] វិធៃ និងឈ្មោះ [redacted] ស៊ីណៃត ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦៥៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ទុកនៅដដែល។ ចំពោះជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន មានឯកសារបញ្ជាក់ថា ជាបុគ្គលិកក្រុមហ៊ុនឡូតូដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ដូចនេះសុំរួចខ្លួនពីបទចោទ។ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះមានសំអាងគ្រប់គ្រាន់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តីបាន។

៤២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បូរ៉ា បានធ្វើសេចក្តីសន្និដ្ឋាន រឿងខាងលើមិនមែនជាការឆបោកទេ គឺជាបទរំលោភលើទំនុកចិត្ត។ ចំពោះល្បែងបាការ៉ាត់ពុំមានភស្តុតាងបញ្ជាក់ថា Website បាការ៉ាត់នោះខុសច្បាប់ដែរ ដូចនេះមិនមែនលេងល្បែងខុសច្បាប់ទេ។ ចំណែកឡូតូ ជាក្រុមហ៊ុនឡូតូស្របច្បាប់ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។ ដូច្នេះស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

៤៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានសុំឱ្យជនជាប់ចោទឈ្មោះ [redacted] នីត និងឈ្មោះ [redacted] ប៊ុនធឿន រួចផុតពីបទចោទ ដោយលើកនូវសំអាងផ្សេងៗ។ ការស្នើសុំនេះតុលាការនឹងលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសម្រេច

១-ឱ្យឈ្មោះ៖

ក-ឈ្មោះ [redacted] នីត ភេទស្រី អាយុ ១៧ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ

រួចខ្លួនពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

២-ផ្តន្ទាទោសឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ ដាក់ទោសពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ពីបទ ឆបោក និងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅភូមិស្រែគ្រោក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ៗ



Scanned with CamScanner

កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៣-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] វិឆៃ ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] ស៊ីណែត ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ

ដាក់ទោសពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ (មួយ) ឆ្នាំ ពីបទ ភ្នាក់ងារស៊ីសងល្បែងខុសច្បាប់ ប្រព្រឹត្តនៅខេត្តកំពង់ស្ពឺ កាលពីអំឡុងឆ្នាំ២០២១ ដល់អំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង។

៤-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៥ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ លើឈ្មោះ [redacted] នីត (KHOEM NIT) និងបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៣៤៧ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ លើឈ្មោះ [redacted] ប៊ុនធឿន ([redacted] BUNTHOEURN) របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

៥-ដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] វិឆៃ (CHHENG VICHAI) លេខ ៣៤៨ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ និងដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ស៊ីណែត (RA SINETH) លេខ ៣៤៦ "ឈ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ អស់អនុភាពអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ។

៦-បង្គាប់ឱ្យចាប់ និងឃុំខ្លួនឈ្មោះ [redacted] វិឆៃ (CHHENG VICHAI) និងឈ្មោះ [redacted] ស៊ីណែត (RA SINETH) ទៅពន្ធនាគារខេត្តកំពង់ស្ពឺ ដើម្បីអនុវត្តតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧-វត្ថុចាប់យកមាន ប្រាក់ដុល្លារចំនួន ២,៣០០ (ពីរពាន់បីរយ) ដុល្លារអាមេរិក និងប្រាក់រៀលចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល រឹបអូសជាសម្បត្តិរដ្ឋ តាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង និងមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ។

៨-ឱ្យឈ្មោះ [redacted] បូរ៉ា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ សងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណី៖

ក-ឈ្មោះ [redacted] នឿន ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក។

ខ-ឈ្មោះ [redacted] សីឡា ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ចំនួន ២៩០,០០០ (ម្ភៃប្រាំបួនម៉ឺន) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក។ ការទាមទារលើសពីនេះច្រានចោល។

គ-ឈ្មោះ [redacted] បូរ៉ាត់ ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ ចំនួន ៨០,០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក។

ឃ-ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ចំនួន ១០៤,០០០ (ដប់ម៉ឺនបួនពាន់) ដុល្លារអាមេរិក។

ង-ឈ្មោះ [redacted] សុភ័ណ្ឌ ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ចំនួន ១៩៨,៣៥០ (ដប់ប្រាំបួនម៉ឺនប្រាំបីពាន់បីរយហាសិប) ដុល្លារអាមេរិក និងជម្ងឺចិត្តចំនួន ១០,០០០ (មួយម៉ឺន) ដុល្លាអាមេរិក។ ការទាមទារលើសពីនេះច្រានចោល។

ច-ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ ចំនួន ១២៧,០០០ (ដប់ពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។

ឆ-ឈ្មោះ [redacted] ចន្ធូ ភេទស្រី អាយុ ៣៦ឆ្នាំ ជាតិខ្មែរ ចំនួន ១៥០,០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ចាត់ទុកជាចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នីត ([redacted]) និងឈ្មោះ [redacted] ប៊ុនធឿន ([redacted]NTHOEURN) កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វិឆៃ (CHHENG VICHAI) និងឈ្មោះ [redacted] ស៊ីណែត [redacted]NETH) ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធឿន, ឈ្មោះ [redacted] សីឡា, ឈ្មោះ [redacted] បូរ៉ាត់, ឈ្មោះ [redacted] វណ្ណា, ឈ្មោះ [redacted] សុភ័ណ្ឌ និងឈ្មោះ [redacted] ចន្ធូ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភា ប្រកាសជាអសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កំពង់ស្ពឺ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]